Fortune
LIFE INSURANCE

ក្រុមហ៊ុន ហ្វ័រឈូន ឡាយហ្វ៍ អ៊ិនសួរេន ម.ក

# បណ្ណសន្យារ៉ាប់រង

# ផលិតផលការពារកម្ចីជាក្រុម ជាមួយ ហ្វ័រឈូន ឡាយហ្វ៍

# មាតិកា


១. និយមន័យ.....02
២. កម្មវត្ថុនៃការធានា.....04
៣. វិសាលភាពនៃការធានា.....04
៤. អត្ថប្រយោជន៍ធានារ៉ាប់រង.....04
៥. ការបង់បុព្វលាភធានារ៉ាប់រង.....05
៦. ករណីមិនធានា.....06
៧. ទីតាំងភូមិសាស្ត្រនៃការធានា.....06
៨. លក្ខណៈសម្បត្តិរបស់អ្នកទទួលផល.....06
៩. ការកែប្រែកិច្ចសន្យាធានារ៉ាប់រង.....07
១០. ការបន្តកិច្ចសន្យាធានារ៉ាប់រង.....08
១១. ការបញ្ចប់កិច្ចសន្យាធានារ៉ាប់រង.....08
១២. ការលុបចោលកិច្ចសន្យាធានារ៉ាប់រង.....08
១៣. ការទាមទារសំណង.....09
១៤. ការរក្សាព័ត៌មានសម្ងាត់.....10
១៥. ការផ្សះផ្សាវិវាទ.....10
១៦. ដែនយុត្តាធិការ.....10
១៧. កាតព្វកិច្ចក្នុងការបង្ហាញព័ត៌មាន.....10

# បណ្ណសន្យារ៉ាប់រង
## ផលិតផលការពារកម្ចីជាក្រុម ជាមួយ ហ្វ័រឈូន ឡាយហ្វ៍

## ១. និយមន័យ

១.១ **ក្រុមហ៊ុន** សំដៅដល់ ក្រុមហ៊ុន ហ្វ័រឈូន ឡាយហ្វ៍ អ៊ិនសួរេន ម.ក។

១.២ **កិច្ចសន្យាធានារ៉ាប់រង** សំដៅដល់កិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ ដែលធ្វើឡើងដោយ ក្រុមហ៊ុន និងម្ចាស់បណ្ណសន្យារ៉ាប់រង ដែលតាមរយៈនោះ ក្រុមហ៊ុនយល់ព្រមទទួលហានិភ័យ ជាក់លាក់ណាមួយនៃអតិថិជនកម្ចីរបស់ម្ចាស់បណ្ណសន្យារ៉ាប់រង ដោយទទួលមកវិញនូវការបង់បុព្វលាភធានារ៉ាប់រងពីម្ចាស់បណ្ណសន្យារ៉ាប់រង។ កិច្ចសន្យាធានារ៉ាប់រង គឺជាបណ្ណសន្យារ៉ាប់រងដែលត្រូវភ្ជាប់ជាមួយដោយវិញ្ញាបនបត្រធានារ៉ាប់រង។

១.៣ **បណ្ណសន្យារ៉ាប់រង** សំដៅដល់ឯកសារចងភ្ជាប់កាតព្វកិច្ច តាមផ្លូវច្បាប់ ដែលចេញដោយក្រុមហ៊ុន ដោយមានកំណត់ពីខ្លឹមសារសំខាន់ និងចែងពីលក្ខខណ្ឌលម្អិត ដែលបានព្រមព្រៀងរវាងក្រុមហ៊ុន និងម្ចាស់បណ្ណសន្យារ៉ាប់រងនៅក្នុងកិច្ចសន្យាធានារ៉ាប់រង។ បណ្ណសន្យារ៉ាប់រងត្រូវភ្ជាប់មកជាមួយនូវវិញ្ញាបនបត្រធានារ៉ាប់រងអាយុជីវិត ឬឯកសារពាក់ព័ន្ធផ្សេងៗទៀត។

១.៤ **ពាក្យស្នើសុំធានារ៉ាប់រង** រាប់បញ្ចូលទាំងទម្រង់បែបបទពាក្យស្នើសុំធានារ៉ាប់រងអាយុជីវិត សេចក្តីថ្លែង និងព័ត៌មានជាលាយលក្ខណ៍អក្សរផ្សេងទៀត ដែលបានចុះហត្ថលេខា និងបានដាក់ជូន ក្រុមហ៊ុន ហ្វ័រឈូន ឡាយហ្វ៍ ដោយផ្ទាល់ ឬជំនួសឱ្យម្ចាស់បណ្ណសន្យារ៉ាប់រង ពាក់ព័ន្ធនឹងការស្នើសុំបណ្ណសន្យារ៉ាប់រងនេះ។

១.៥ **ម្ចាស់បណ្ណសន្យារ៉ាប់រង** សំដៅដល់នីតិបុគ្គលដែលជាគ្រឹះស្ថានហិរញ្ញវត្ថុដែលមានសិទ្ធិស្របច្បាប់លើបណ្ណសន្យារ៉ាប់រង ឬ បុគ្គលទាំងឡាយណាជាអ្នកតំណាងស្របច្បាប់នៃនីតិបុគ្គលនោះដែលមានអាយុចាប់ពី ដប់ប្រាំបី (១៨) ឆ្នាំឡើងទៅ មានសមត្ថភាពពេញលេញ និងជាអ្នកដែលបានបំពេញ និងចុះហត្ថលេខា លើទម្រង់បែបបទពាក្យស្នើសុំធានារ៉ាប់រង ឬជាអ្នកផ្ទេរសិទ្ធិឱ្យគេបំពេញ និងចុះហត្ថលេខា លើទម្រង់បែបបទពាក្យស្នើសុំធានារ៉ាប់រងជំនួស និងជាអ្នកបង់បុព្វលាភធានារ៉ាប់រង។

១.៦ **គ្រឹះស្ថានហិរញ្ញវត្ថុ** សំដៅដល់ស្ថាប័នផ្តល់កម្ចី ក្នុងស្រុក ឬអន្តរជាតិ និងស្ថាប័នដទៃទៀតដែលត្រូវបាន អនុញ្ញាតឱ្យផ្តល់កម្ចីដល់បុគ្គល ដែលស្ថិតក្រោម បទបញ្ញត្តិនៃកិច្ចសន្យាកម្ចី នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

១.៧ **ឥណវន្ត** សំដៅដល់រូបវន្តបុគ្គលដែលជាប់បំណុល ឬទទួលបានកម្ចីពីម្ចាស់បណ្ណសន្យារ៉ាប់រងនៃបណ្ណសន្យារ៉ាប់រងនេះដែលជាគ្រឹះស្ថានហិរញ្ញវត្ថុ។

១.៨ **អ្នកត្រូវបានធានារ៉ាប់រង** សំដៅដល់រូបវន្តបុគ្គលដែលជាឥណវន្ត ក្រោមលក្ខខណ្ឌកិច្ចព្រមព្រៀងឥណទានរបស់ម្ចាស់បណ្ណសន្យារ៉ាប់រង ហើយដែលអាចទទួលបានការធានារ៉ាប់រង ស្របទៅតាមលក្ខខណ្ឌដែលត្រូវបានព្រមព្រៀងរវាងក្រុមហ៊ុនធានារ៉ាប់រង និងម្ចាស់បណ្ណសន្យារ៉ាប់រង ហើយមានឈ្មោះក្នុងបញ្ជីអ្នកត្រូវបានធានារ៉ាប់រង កិច្ចសន្យាបន្ថែម ឬលិខិតបញ្ជាក់ការផ្លាស់ប្តូរលើបណ្ណសន្យារ៉ាប់រងនេះ។

១.៩ **អ្នកទទួលផល** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលត្រូវបានកំណត់ថាមានសិទ្ធិស្របច្បាប់ក្នុងការទទួលផលប្រយោជន៍ពីកិច្ចសន្យាទាំងឡាយណាដែលទាក់ទង នឹងការធានារ៉ាប់រងលើអាយុជីវិតតែប៉ុណ្ណោះ។

**អ្នកទទួលផលចម្បង** សំដៅដល់គ្រឹះស្ថានហិរញ្ញវត្ថុ ដែលជាម្ចាស់បណ្ណសន្យារ៉ាប់រង ហើយដែលជាអ្នកផ្តល់កម្ចីដល់អ្នកត្រូវបានធានារ៉ាប់រងនៃបណ្ណសន្យារ៉ាប់រងនេះ។

**អ្នកទទួលផលបន្ទាប់បន្សំ** សំដៅដល់បុគ្គល ដែលត្រូវបានបញ្ជាក់នៅក្នុងបញ្ជីអ្នកត្រូវបានធានារ៉ាប់រង ឬ បញ្ជីបន្ថែម/លុបចោលអ្នកត្រូវបានធានារ៉ាប់រង ឬឯកសារភ្ជាប់ផ្សេងៗទៀតនៃបណ្ណសន្យារ៉ាប់រងនេះ ដោយម្ចាស់បណ្ណសន្យារ៉ាប់រង ថាជាអ្នកទទួលផលបន្ទាប់បន្សំ ដើម្បីទទួលអត្ថប្រយោជន៍ធានារ៉ាប់រង ដែលនៅសល់បន្ទាប់ ពីការដកចេញនូវទឹកប្រាក់ធានារ៉ាប់រងដែលត្រូវទូទាត់ ទៅអ្នកទទួលផលចម្បងយោងតាមខ និង លក្ខខណ្ឌនៃបណ្ណសន្យារ៉ាប់រងនេះ។

១.១០ **ចំនួនទឹកប្រាក់ធានារ៉ាប់រង** សំដៅដល់ចំនួនទឹកប្រាក់នៃការធានារ៉ាប់រងរបស់អ្នកត្រូវបានធានារ៉ាប់រងម្នាក់ៗ ដែល៖

- ស្មើនឹងកម្ចីដែលនៅជំពាក់ - សម្រាប់ប្រភេទទឹកប្រាក់ធានារ៉ាប់រងថយចុះ (ស្របទៅតាមនិយមន័យដូចខាងក្រោម)ឬ
- ស្មើនឹងទឹកប្រាក់ធានារ៉ាប់រងដូចបញ្ជាក់នៅក្នុងបញ្ជីអ្នកត្រូវបានធានារ៉ាប់រង ឬបញ្ជីបន្ថែម/លុបចោលអ្នកត្រូវបានធានារ៉ាប់រង និងត្រូវបានបញ្ជាក់នៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រងអាយុជីវិតលើកម្ចីជាក្រុម ឬកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរផ្សេងទៀត។

**ចំនួនទឹកប្រាក់ធានារ៉ាប់រងថេរ** មានន័យថាចំនួនទឹកប្រាក់នៃការធានារ៉ាប់រងដែលមានចំនួនថេរក្នុងអំឡុងរយៈពេលនៃបណ្ណសន្យារ៉ាប់រង។

**ចំនួនទឹកប្រាក់ធានារ៉ាប់រងថយចុះ** មានន័យថា ចំនួនទឹកប្រាក់នៃការធានារ៉ាប់រង ដែលថយចុះពីមួយខែទៅមួយខែ អាស្រ័យលើអត្រាការប្រាក់មូលដ្ឋាន និងរយៈពេលនៃបណ្ណសន្យារ៉ាប់រង និងដោយផ្អែកតាមវិធីសាស្ត្រគណនា ដែលត្រូវបានយល់ព្រមរវាងក្រុមហ៊ុនធានារ៉ាប់រង និងម្ចាស់បណ្ណសន្យារ៉ាប់រង។ ចំនួនទឹកប្រាក់ធានារ៉ាប់រងនឹងត្រូវទូទាត់ដោយមិនគិតពីសមតុល្យ ប្រាក់កម្ចីជាក់ស្តែង។

១.១១ **បុព្វលាភធានារ៉ាប់រង** សំដៅដល់ចំនួនទឹកប្រាក់ដែលម្ចាស់បណ្ណសន្យារ៉ាប់រងត្រូវបង់ទៅឱ្យក្រុមហ៊ុនធានារ៉ាប់រង តាមការកំណត់របស់ក្រុមហ៊ុនធានារ៉ាប់រងនៅក្នុងបណ្ណសន្យារ៉ាប់រងនេះ។

១.១២ **បុព្វលាភធានារ៉ាប់រងដែលត្រូវបង់ម្តងៗ** សំដៅលើទឹកប្រាក់បុព្វលាភធានារ៉ាប់រង ដោយផ្អែកលើរបៀបនៃការបង់បុព្វលាភធានារ៉ាប់រង និងដូចដែលបានបញ្ជាក់នៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រងអាយុជីវិតលើកម្ចីជាក្រុម ។

១.១៣ **កាលបរិច្ឆេទចាប់ផ្តើមបណ្ណសន្យារ៉ាប់រង** សំដៅដល់កាលបរិច្ឆេទបង្ហាញនៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រងអាយុជីវិតលើកម្ចីជាក្រុម ដែលក្រុមហ៊ុនហ្វ័រឈូន ឡាយហ្វ៍ បានទទួលស្គាល់លើពាក្យស្នើសុំធានារ៉ាប់រង រួមជាមួយបញ្ជីអ្នកត្រូវបានធានារ៉ាប់រងពេញលេញ ពីម្ចាស់បណ្ណសន្យារ៉ាប់រង។ ប្រសិនបើកាលបរិច្ឆេទនៃការទទួលបានបុព្វលាភធានារ៉ាប់រងដំបូង និងពាក្យស្នើសុំធានារ៉ាប់រងស្ថិតក្នុងពេលផ្សេងគ្នា នោះកាលបរិច្ឆេទចាប់ផ្តើមបណ្ណសន្យារ៉ាប់រងនឹងស្របទៅតាមកាលបរិច្ឆេទដែលម្ចាស់បណ្ណសន្យារ៉ាប់រងស្នើសុំការការពារពីក្រុមហ៊ុន ជាលាយលក្ខណ៍អក្សរ និងក្រោយពាក្យស្នើសុំត្រូវបានទទួលយកដោយក្រុមហ៊ុនតែប៉ុណ្ណោះ។

ប្រសិនបើកាលបរិច្ឆេទចាប់ផ្តើមបណ្ណសន្យារ៉ាប់រងកើតឡើងមុនកាលបរិច្ឆេទនៃការទទួលបាន បុព្វលាភធានារ៉ាប់រងដំបូង ម្ចាស់បណ្ណសន្យារ៉ាប់រងត្រូវមានកាតព្វកិច្ចទូទាត់បុព្វលាភធានារ៉ាប់រងជូនដល់ក្រុមហ៊ុនយ៉ាងយូរបំផុត ១០ ថ្ងៃបន្ទាប់ពីថ្ងៃចេញវិក័យបត្រដោយក្រុមហ៊ុន ឬ ក្នុងរយៈពេល ១០ ថ្ងៃនៃការបិទបញ្ចប់ខែនីមួយៗ តាមការកំណត់របស់ក្រុមហ៊ុន។

ប្រសិនបើម្ចាស់បណ្ណសន្យារ៉ាប់រង មិនបានទូទាត់បុព្វលាភធានារ៉ាប់រងក្នុងរយៈពេល ១០ ថ្ងៃបន្ទាប់ពីថ្ងៃចេញវិក័យបត្រដោយក្រុមហ៊ុន ឬក្នុងរយៈពេល ១០ ថ្ងៃនៃការបិទបញ្ចប់ខែនីមួយៗ តាមការកំណត់របស់ក្រុមហ៊ុននោះទេ ការធានារ៉ាប់រងក្រោមបណ្ណសន្យារ៉ាប់រងនេះនឹងត្រូវចាត់ទុកថាគ្មានសុពលភាពចាប់តាំងពីកាលបរិច្ឆេទចាប់ផ្តើមបណ្ណសន្យារ៉ាប់រង។

ក្នុងករណីមានព្រឹត្តិការណ៍ដែលត្រូវបានធានា កើតឡើងក្នុងចន្លោះរវាងកាលបរិច្ឆេទចាប់ផ្តើមបណ្ណសន្យារ៉ាប់រង និងកាលបរិច្ឆេទនៃការទទួលបានបុព្វលាភធានារ៉ាប់រងដំបូងដោយក្រុមហ៊ុន នោះបុព្វលាភធានារ៉ាប់រងដែលមិនទាន់បានបង់ នឹងត្រូវកាត់ចេញពីទឹកប្រាក់នៃសំណងដែល ក្រុមហ៊ុននឹងត្រូវទូទាត់ក្រោមបណ្ណសន្យារ៉ាប់រងនេះ ដោយមិនគិតការប្រាក់។

១.១៤ **កាលបរិច្ឆេទដល់កាលកំណត់បង់បុព្វលាភធានារ៉ាប់រង** សំដៅដល់កាលបរិច្ឆេទដែលត្រូវបង់បុព្វលាភធានារ៉ាប់រង ផ្អែកទៅតាមរបៀបបង់ បុព្វលាភធានារ៉ាប់រង (ឧទាហរណ៍ ជាត្រីមាស ម្តង) ដែលម្ចាស់បណ្ណសន្យារ៉ាប់រងបានជ្រើសរើស។ រាល់អ្នកត្រូវបានធានារ៉ាប់រងទាំងអស់ក្រោមបណ្ណសន្យារ៉ាប់រងនេះ ត្រូវមានកាលបរិច្ឆេទដល់កាលកំណត់បង់បុព្វលាភធានារ៉ាប់រងដូចគ្នា។

១.១៥ **កាលបរិច្ឆេទក្លាយជាអ្នកត្រូវបានធានារ៉ាប់រង** សំដៅលើកាលបរិច្ឆេទដែលកម្ចីរបស់ខ្លួនត្រូវបានផ្តល់ ជូនដោយម្ចាស់បណ្ណសន្យារ៉ាប់រង ដូចដែលមានបញ្ជាក់នៅក្នុងបញ្ជីអ្នកត្រូវបានធានារ៉ាប់រង ឬ បញ្ជីបន្ថែម/លុបចោលអ្នកត្រូវបានធានារ៉ាប់រង ឬកិច្ចសន្យាបន្ថែម ឬលិខិតបញ្ជាក់ការផ្លាស់ប្តូរ (ដែលបង្ហាញពីពេលវេលាដែលអតិថិជនកម្ចីចាប់ផ្តើមមានសិទ្ធិទទួលបានការធានារ៉ាប់រងស្ថិតក្រោមបណ្ណសន្យារ៉ាប់រងនេះ) ដែលត្រូវបានយល់ព្រមដោយក្រុមហ៊ុនធានារ៉ាប់រង។

១.១៦ **កាលបរិច្ឆេទដល់កាលកំណត់** សំដៅលើកាលបរិច្ឆេទដូចដែលមានបញ្ជាក់លើវិញ្ញាបនបត្រធានារ៉ាប់រងអាយុជីវិតលើកម្ចីជាក្រុម កិច្ចសន្យាបន្ថែម ឬលិខិតបញ្ជាក់ការផ្លាស់ប្តូរ ដែលបង្ហាញពីពេលវេលាដែលសុពលភាពរបស់បណ្ណសន្យារ៉ាប់រងនេះត្រូវបញ្ចប់។ រាល់អ្នកត្រូវបានធានារ៉ាប់រងនៃបណ្ណសន្យារ៉ាប់រងនេះ ត្រូវមានកាលបរិច្ឆេទដល់កាលកំណត់ដូចគ្នា។

១.១៧ **វិញ្ញាបនបត្រធានារ៉ាប់រងអាយុជីវិតលើកម្ចីជាក្រុម** សំដៅលើ ឯកសារភ្ជាប់ដែលចេញដោយក្រុមហ៊ុនធានារ៉ាប់រងជូនដល់ម្ចាស់បណ្ណសន្យារ៉ាប់រង បញ្ជាក់ពីការផ្តល់ជូននូវការធានារ៉ាប់រងដែលបានស្នើសុំដោយម្ចាស់បណ្ណសន្យារ៉ាប់រងដោយមានភ្ជាប់នូវសេចក្តីលម្អិតសំខាន់ផ្សេងៗដែលបង្កើតបានជាផ្នែកមួយនៃបណ្ណសន្យារ៉ាប់រងនេះ។

១.១៨ **បញ្ជីអ្នកត្រូវបានធានារ៉ាប់រង** សំដៅដល់តារាងដែលជាផ្នែកមួយនៃបណ្ណសន្យារ៉ាប់រងនេះ ដែលបង្ហាញពីអតិថិជនកម្ចីដែលស្ថិតក្រោមការការពារនៃបណ្ណសន្យារ៉ាប់រងនេះ។ ក្នុងករណីមានការប្រែប្រួល អ្នកត្រូវបានធានារ៉ាប់រង បន្ទាប់ពីកាលបរិច្ឆេទចាប់ផ្តើមបណ្ណសន្យារ៉ាប់រងនេះ កិច្ចសន្យាបន្ថែម ឬលិខិតបញ្ជាក់ការផ្លាស់ប្តូរបន្តបន្ទាប់ផ្សេងៗទៀតនឹងមានសុពលភាពជំនួស។

១.១៩ **ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ (TPD)** សំដៅដល់ការបាត់បង់ទាំងស្រុង ឬខ្វិនទាំងស្រុង និងជាអចិន្ត្រៃយ៍ ឬបាត់បង់សមត្ថភាពប្រើប្រាស់ទាំងស្រុង និងមិនអាចជាសះស្បើយជាអចិន្ត្រៃយ៍នូវ៖

- បាត់បង់នូវសមត្ថភាពមើលឃើញនៃភ្នែកទាំងពីរ ឬ
- ការដាច់ចេញ ឬបាត់បង់នូវសមត្ថភាពប្រើប្រាស់ទាំងស្រុងនៃដៃទាំងពីរ គិតចាប់ពីកដៃឡើងទៅ ឬ
- ការដាច់ចេញ ឬបាត់បង់នូវសមត្ថភាពប្រើប្រាស់ទាំងស្រុងនៃជើងទាំងពីរ គិតចាប់ពីកជើងឡើងទៅ ឬ
- ភាពខ្វាក់ទាំងស្រុងនៃភ្នែកម្ខាង និងការដាច់ចេញ ឬបាត់បង់នូវសមត្ថភាពប្រើប្រាស់ ទាំងស្រុងនៃដៃម្ខាង គិតចាប់ពីកដៃឡើងទៅ ឬ

- ភាពខ្វាក់ទាំងស្រុងនៃភ្នែកម្ខាង និងការដាច់ចេញ ឬបាត់បង់នូវសមត្ថភាពប្រើប្រាស់ ទាំងស្រុងនៃជើងម្ខាង គិតចាប់ពីកជើងឡើងទៅ ឬ
- ការដាច់ចេញ ឬបាត់បង់នូវសមត្ថភាពប្រើប្រាស់ទាំងស្រុងនៃជើងម្ខាង គិតចាប់ពីកជើងឡើងទៅ និងការដាច់ចេញ ឬបាត់បង់នូវសមត្ថភាពប្រើប្រាស់ទាំងស្រុងនៃដៃម្ខាង គិតចាប់ពីកដៃឡើងទៅ។

១.២០ **ស្ថានភាពសុខភាពកើតមុនពេលធានារ៉ាប់រង** សំដៅទៅលើស្ថានភាពសុខភាពរបស់អ្នកត្រូវបានធានារ៉ាប់រងដែលកើតមានមុនកាលបរិច្ឆេទចាប់ផ្តើមនៃបណ្ណសន្យារ៉ាប់រងនេះ ឬមុនកាលបរិច្ឆេទក្លាយជាអ្នកត្រូវបានធានារ៉ាប់រងរ៉ាប់រង ឬមុនពេលកម្ចីរបស់ខ្លួនត្រូវបានផ្តល់ជូនដោយម្ចាស់បណ្ណសន្យារ៉ាប់រង ឬកាលបរិច្ឆេទបន្តសុពលភាពឡើងវិញបន្ទាប់ពីការអស់សុពលភាពជាបណ្តោះអាសន្ននៃបណ្ណសន្យារ៉ាប់រងនេះ (ដោយយកកាលបរិច្ឆេទណាមួយចុងក្រោយគេបំផុត) លុះត្រាតែស្ថានភាពសុខភាពទាំងនោះត្រូវបានប្រកាសដោយអ្នកត្រូវបានធានារ៉ាប់រង ឬម្ចាស់បណ្ណសន្យារ៉ាប់រង និងទទួលយកដោយក្រុមហ៊ុនធានារ៉ាប់រង។

ស្ថានភាពសុខភាពដែលកើតមុនពេលធានារ៉ាប់រងសំដៅដល់៖

ក) ជំងឺ មេរោគ ឬភាពចុះខ្សោយ ឬរបួសផ្សេងៗដែលអ្នកត្រូវបានធានារ៉ាប់រង ធ្លាប់ទទួលការប្រឹក្សាយោបល់ ស្វែងរកការព្យាបាល ឬទទួលការព្យាបាល ឬ

ខ) ការលេចឡើងពីមុននៃសញ្ញា ឬរោគសញ្ញាផ្សេងៗណាមួយ ដែលនាំឲ្យមនុស្សជាទូទៅស្វែងរកការព្យាបាល ការធ្វើរោគវិនិច្ឆ័យ ឬធ្វើការព្យាបាលឲ្យជាសះស្បើយ។

១.២១ **រយៈពេលរង់ចាំ** ក្រុមហ៊ុននឹងមិនធ្វើការទូទាត់ជូននូវអត្ថប្រយោជន៍មរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍នៃបណ្ណសន្យារ៉ាប់រងនេះឡើយ ប្រសិនបើការធ្វើវិនិច្ឆ័យឃើញថាមរណភាព ឬពិការភាពរបស់អ្នកត្រូវបានធានារ៉ាប់រងបណ្តាលមកពីជំងឺនៅក្នុងរយៈពេលត្រឹម ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទចាប់ផ្តើមបណ្ណសន្យារ៉ាប់រង ឬមុនកាលបរិច្ឆេទក្លាយជាអ្នកត្រូវបានធានារ៉ាប់រង ឬមុនពេលកម្ចីរបស់ខ្លួនត្រូវបានផ្តល់ជូនដោយម្ចាស់បណ្ណសន្យារ៉ាប់រង ឬមុនកាលបរិច្ឆេទបន្តសុពលភាពឡើងវិញបន្ទាប់ពីការអស់សុពលភាពជាបណ្តោះអាសន្ននៃបណ្ណសន្យារ៉ាប់រងនេះ(ដោយយកកាលបរិច្ឆេទណាមួយចុងក្រោយគេបំផុត)។

១.២២ **ច្បាប់កម្ពុជា** សំដៅដល់ច្បាប់ និងបទបញ្ញត្តិនានានៃព្រះរាជាណាចក្រកម្ពុជាដែលកំពុងអនុវត្តរួមទាំងវិសោធនកម្មនានាដែលពាក់ព័ន្ធ។

## ២. កម្មវត្ថុនៃការធានា

បណ្ណសន្យារ៉ាប់រងនេះផ្តល់ជូនការការពារដល់អតិថិជនកម្ចីដែលក្លាយជាអ្នកត្រូវបានធានារ៉ាប់រងក្រោមបណ្ណសន្យារ៉ាប់រងនេះ លើរូបរាងកាយ និងអាយុជីវិត។

## ៣. វិសាលភាពនៃការធានា

បណ្ណសន្យារ៉ាប់រងនេះ ផ្តល់ការការពារនៅក្នុងប្រទេសកម្ពុជា (ផ្អែកតាម ខ និងលក្ខខណ្ឌផ្សេងៗទៀត ដែលមានចែងក្នុងបណ្ណសន្យារ៉ាប់រងនេះ) សម្រាប់អ្នកត្រូវបានធានារ៉ាប់រង ទៅលើមរណភាព និង ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍។

## ៤. អត្ថប្រយោជន៍ធានារ៉ាប់រង

យោងតាមបណ្ណសន្យារ៉ាប់រងនេះ ក្រុមហ៊ុនធានារ៉ាប់រងនឹងទូទាត់អត្ថប្រយោជន៍ធានារ៉ាប់រង នៅពេលដែលក្រុមហ៊ុនទទួលបានភស្តុតាងត្រឹមត្រូវ និងពិតប្រាកដអំពី មរណភាព ឬពិការភាពទាំងស្រុងនិងជាអចិន្ត្រៃយ៍របស់អ្នកត្រូវបានធានារ៉ាប់រងនៃបណ្ណសន្យារ៉ាប់រងនេះ។

ទឹកប្រាក់សរុបដែលត្រូវទូទាត់ដោយក្រុមហ៊ុនធានារ៉ាប់រងស្មើនឹងអត្ថប្រយោជន៍មរណភាពឬពិការភាពទាំងស្រុងនិងជាអចិន្ត្រៃយ៍ ដូចត្រូវបានបង្ហាញនៅ ក្នុងផ្នែក ៤.១ និង ៤.២ ខាងក្រោម ដកចេញនូវបុព្វលាភធានារ៉ាប់រងដែលមិនទាន់បានទូទាត់ណាមួយជាមួយនឹងការប្រាក់បង្គរ និងចំណាយ រួមទាំងពន្ធដែលពាក់ព័ន្ធផ្សេងៗ (ប្រសិនបើមាន)។

៤.១ **ករណីម្ចាស់បណ្ណសន្យារ៉ាប់រងជ្រើសរើសប្រភេទទឹកប្រាក់ធានារ៉ាប់រងថេរ៖**

១០០% នៃទឹកប្រាក់ធានារ៉ាប់រងដូចដែលបានបង្ហាញនៅក្នុងបញ្ជីអ្នកត្រូវបានធានារ៉ាប់រង ឬបញ្ជីបន្ថែម/លុបចោលអ្នកត្រូវបានធានារ៉ាប់រង នៃបណ្ណសន្យារ៉ាប់រងនេះនឹងត្រូវបានទូទាត់ក្នុងករណីមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍របស់អ្នកត្រូវបានធានារ៉ាប់រង ដោយ៖

ក) ទឹកប្រាក់ធានារ៉ាប់រងនោះ នឹងត្រូវបានទូទាត់ ដល់អ្នកទទួលផលចម្បងជាមុនសម្រាប់ទឹកប្រាក់កម្ចីដែលអ្នកត្រូវបានធានារ៉ាប់រងនៅជំពាក់ម្ចាស់បណ្ណសន្យារ៉ាប់រង និង

ខ) ទឹកប្រាក់ដែលនៅសល់ (ប្រសិនបើមាន) បន្ទាប់ពីទូទាត់ទឹកប្រាក់កម្ចីដែលនៅជំពាក់ នឹងត្រូវទូទាត់ជូនអ្នកត្រូវបានធានារ៉ាប់រង ឬអ្នកទទួលផលបន្ទាប់បន្សំរបស់អ្នកត្រូវបានធានារ៉ាប់រង។

**៤.២ ករណីម្ចាស់បណ្ណសន្យារ៉ាប់រងជ្រើសរើសប្រភេទទឹកប្រាក់ធានារ៉ាប់រងថយចុះ៖**

១០០% នៃទឹកប្រាក់ធានារ៉ាប់រងថយចុះតាមថេរវេលា ផ្អែកតាមវិធីសាស្រ្តគណនា ដែលត្រូវបានយល់ព្រមរវាងក្រុមហ៊ុនធានារ៉ាប់រង និងម្ចាស់បណ្ណសន្យារ៉ាប់រងជាមុន នឹងត្រូវបានទូទាត់ជូនអ្នកទទួលផលចម្បង ក្នុងករណីមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍របស់អ្នកត្រូវបានធានារ៉ាប់រង។

ក្នុងករណីដែលអត្ថប្រយោជន៍មរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ របស់អ្នកត្រូវបានធានារ៉ាប់រង ត្រូវបានទូទាត់រួច ការធានារ៉ាប់រងសម្រាប់អ្នកត្រូវបានធានារ៉ាប់រងនោះនឹងត្រូវបញ្ចប់ផងដែរ។

## ៥. ការបង់បុព្វលាភធានារ៉ាប់រង

ការបង់បុព្វលាភធានារ៉ាប់រង និងរបៀបនៃការបង់បុព្វលាភធានារ៉ាប់រង ត្រូវបានបញ្ជាក់នៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រងអាយុជីវិតលើកម្ចីជាក្រុម ឬឯកសារបញ្ជាក់ការផ្លាស់ប្តូរចុងក្រោយបន្ថែមផ្សេងទៀត (ប្រសិនបើមាន)។

បុព្វលាភធានារ៉ាប់រងដំបូងត្រូវបង់ចាប់ពីកាលបរិច្ឆេទចាប់ផ្តើមបណ្ណសន្យារ៉ាប់រង ក្នុងរយៈពេល ១០ ថ្ងៃបន្ទាប់ពីថ្ងៃចេញវិក័យបត្រដោយក្រុមហ៊ុនធានារ៉ាប់រង ឬ ក្នុងរយៈពេល ១០ ថ្ងៃនៃការបិទបញ្ចប់ខែនីមួយៗ តាមការកំណត់របស់ក្រុមហ៊ុន ហើយបុព្វលាភបន្តបន្ទាប់ត្រូវដល់កំណត់ នឹងត្រូវបង់នៅកាលបរិច្ឆេទដល់កាលកំណត់បង់បុព្វលាភធានារ៉ាប់រងដែលត្រូវ បានកំណត់នៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រងអាយុជីវិតលើកម្ចីជាក្រុម តាមរបៀបដូចគ្នានឹងការបង់បុព្វលាភធានារ៉ាប់រងដំបូងដែរ។ ម្ចាស់បណ្ណសន្យារ៉ាប់រង ត្រូវទទួលខុសត្រូវក្នុងការបង់ពន្ធ ដែលពាក់ព័ន្ធក្នុងការចេញបណ្ណសន្យារ៉ាប់រងនេះ (ប្រសិនបើមាន)។

ការបង់បុព្វលាភធានារ៉ាប់រងនេះ អាចធ្វើបានតាមរយៈ៖

- ការផ្ទេរប្រាក់ចូលគណនីធនាគាររបស់ក្រុមហ៊ុន ហ្វ័រឈូន ឡាយហ្វ៍ អ៊ិនសួរេន ម.ក ឬ
- បញ្ជាបង់ប្រាក់អចិន្ត្រៃយ៍ ឬ
- វិធីសាស្រ្តបង់បុព្វលាភធានារ៉ាប់រងផ្សេងៗទៀត ដែលយល់ព្រមពីភាគីទាំងសងខាង។

បន្ទាប់ពីការទូទាត់បុព្វលាភធានារ៉ាប់រងដំបូង ម្ចាស់បណ្ណសន្យារ៉ាប់រង ត្រូវបង់បុព្វលាភធានារ៉ាប់រងបន្តបន្ទាប់ទៅតាមថ្ងៃដល់កាលកំណត់បង់បុព្វលាភធានារ៉ាប់រង ហើយការធានារ៉ាប់រងនឹងបន្តឡើងដោយស្វ័យប្រវត្តិ។

ប្រសិនបើម្ចាស់បណ្ណសន្យារ៉ាប់រងខកខាននូវការទូទាត់បុព្វលាភធានារ៉ាប់រងបន្ទាប់ (ក្នុងករណីម្ចាស់បណ្ណសន្យារ៉ាប់រងបានជ្រើសរើសការបង់បុព្វលាភធានារ៉ាប់រងជាប្រចាំ ឧ. ប្រចាំឆ្នាំ) នៅត្រឹម ឬមុនកាលបរិច្ឆេទដល់កាលកំណត់ត្រូវបង់បុព្វលាភធានារ៉ាប់រងដល់ក្រុមហ៊ុន យោងទៅតាមការអនុវត្តការបង់ប្រាក់របស់ក្រុមហ៊ុន នោះនឹងត្រូវបានចាត់ទុកថាជាការខកខានមិនបានបង់បុព្វលាភធានារ៉ាប់រង។ រយៈពេលអនុគ្រោះចំនួន ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដល់កាលកំណត់ត្រូវបង់បុព្វលាភធានារ៉ាប់រង នឹងត្រូវបានផ្តល់ជូនសម្រាប់ការទូទាត់បុព្វលាភធានារ៉ាប់រងដែលមិនទាន់បានបង់ ដែលក្នុងរយៈពេលអនុគ្រោះនេះ បណ្ណសន្យារ៉ាប់រងនេះនឹងនៅតែមានសុពលភាពដដែល។ ប្រសិនបើក្រុមហ៊ុននៅតែមិនទទួលបាននូវបុព្វលាភធានារ៉ាប់រង គិតត្រឹមកាលបរិច្ឆេទចុងក្រោយនៃរយៈពេលអនុគ្រោះ នោះបណ្ណសន្យារ៉ាប់រងនេះ នឹងផុតសុពលភាព គិតចាប់ពីកាលបរិច្ឆេទដែលត្រូវបង់បុព្វលាភធានារ៉ាប់រងចុងក្រោយ ដោយមិនចាំបាច់មានការជូនដំណឹងដល់ម្ចាស់បណ្ណសន្យារ៉ាប់រងឡើយ។ ការទទួលខុសត្រូវរបស់ក្រុមហ៊ុនធានារ៉ាប់រងនៅក្រោមបណ្ណសន្យារ៉ាប់រងនេះនឹងត្រូវបញ្ចប់ ហើយក្រុមហ៊ុននឹងមិនត្រូវប្រគល់ជូនវិញនូវរាល់បុព្វលាភធានារ៉ាប់រងដែលបានបង់រួចនោះឡើយ។

ក្នុងករណីរយៈពេលអនុគ្រោះ ឬ រយៈពេលអនុញ្ញាត ១០ ថ្ងៃបន្ទាប់ពីថ្ងៃចេញវិក័យបត្រដោយក្រុមហ៊ុន ឬ ក្នុងរយៈពេល ១០ ថ្ងៃនៃការបិទបញ្ចប់ខែនីមួយៗ ដែលអនុគ្រោះដោយក្រុមហ៊ុន នោះក្រុមហ៊ុននឹងយកកាលបរិច្ឆេទណាដែលដល់កំណត់ចុងក្រោយគេបង្អស់ មកអនុវត្ត ឬកំណត់ការផុតសុពលភាពរបស់បណ្ណសន្យារ៉ាប់រង ឬ អ្នកត្រូវបានធានារ៉ាប់រង។

ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ នៅរយៈពេលអនុគ្រោះនេះ នោះរាល់បុព្វលាភធានារ៉ាប់រងដែលមិនទាន់បានទូទាត់នៅក្នុងឆ្នាំបណ្ណសន្យារ៉ាប់រងនេះ នឹងត្រូវបានកាត់ចេញពីចំនួនទឹកប្រាក់សំណង ដែលក្រុមហ៊ុននឹងទូទាត់ជូននៅក្រោមបណ្ណសន្យារ៉ាប់រងនេះដោយមិនមានការប្រាក់។

## ៦. ករណីមិនធានា

**អត្ថប្រយោជន៍ក្នុងករណីមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍៖**

រាល់ការទាមទារសំណងចំពោះមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍របស់អ្នកត្រូវបានធានារ៉ាប់រងទាំងឡាយណាដែលកើតឡើងដោយផ្ទាល់ ឬប្រយោលដោយមូលហេតុខាងក្រោម នឹងមិនត្រូវបានធានាឡើយ៖

ក) ការធ្វើអត្តឃាត ឬប៉ុនប៉ងធ្វើអត្តឃាត ឬបង្កគ្រោះថ្នាក់ដោយខ្លួនឯង ទោះជាក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតីក៏ដោយ ឬ

ខ) ការឆ្លងមេរោគហ៊ីវ(HIV) ឬជំងឺអេដស៍(AIDS) ឬជំងឺផ្សេងៗទៀតដែលពាក់ព័ន្ធនឹងមេរោគហ៊ីវ (HIV) ឬជំងឺអេដស៍ (AIDS) ឬ

គ) ការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ការសេពគ្រឿងស្រវឹងហួសកម្រិត ឬបើកបរយានជំនិះក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន ឬ

ឃ)ការចូលរួមក្នុងសកម្មភាពខុសច្បាប់ ឬប្រឆាំងនឹងការចាប់ខ្លួនរបស់អាជ្ញាធរ ឬសកម្មភាពលួចចេញពីពន្ធនាគារ ឬ

ង) ការប្រព្រឹត្ត ឬការប៉ុនប៉ងប្រព្រឹត្តដោយអ្នកត្រូវបានធានារ៉ាប់រង ឬអ្នកទទួលផលបន្ទាប់បន្សំ ឬម្ចាស់បណ្ណសន្យារ៉ាប់រងនូវរាល់បទល្មើសព្រហ្មទណ្ឌដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមានដែលបង្កឱ្យអ្នកត្រូវបានធានារ៉ាប់រង ទទួលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ឬ

ច) ពិការភាពរបស់អ្នកត្រូវបានធានារ៉ាប់រង ដែលកើតឡើងមុនពេលកាលបរិច្ឆេទចាប់ផ្តើមបណ្ណសន្យារ៉ាប់រង ឬមុនកាលបរិច្ឆេទក្លាយជាអ្នកត្រូវបានធានារ៉ាប់រង ឬមុនពេលកម្ចីរបស់ខ្លួនត្រូវបានផ្តល់ជូនដោយម្ចាស់បណ្ណសន្យារ៉ាប់រង ឬមុនកាលបរិច្ឆេទបន្តសុពលភាពឡើងវិញបន្ទាប់ពីការអស់សុពលភាពជាបណ្តោះអាសន្ននៃបណ្ណសន្យារ៉ាប់រងនេះ (ដោយយកកាលបរិច្ឆេទណាមួយចុងក្រោយគេបំផុត) ឬ

ឆ) ការចូលរួមរបស់អ្នកត្រូវបានធានារ៉ាប់រង ក្នុងសកម្មភាពសង្គ្រាម ឬក្នុងអំឡុងពេលមានសង្គ្រាម ឬ នៅក្នុងប្រតិបត្តិការសង្គ្រាម (ទោះមាន ឬមិនមានការប្រកាសជាមុនក៏ដោយ) ឬ សង្គ្រាមស៊ីវិល ឬ ការស្តារសណ្តាប់ធ្នាប់សាធារណៈ ក្នុងកំឡុងពេលមានការបះបោរ អំពើហិង្សារបដិវត្តន៍ កុប្បកម្ម ឬជម្លោះប្រដាប់អាវុធផ្សេងៗ ឬ គ្រោះមហន្តរាយជាដើម ឬ

ជ) ការចូលរួមរបស់អ្នកត្រូវបានធានារ៉ាប់រង នៅក្នុងសកម្មភាពហោះហើរ ឬអាកាសចរណ៍នានា លើកលែងតែអ្នកត្រូវបានធានារ៉ាប់រងនោះជាអ្នកដំណើរត្រូវបង់ថ្លៃធ្វើដំណើរនៃអាកាសចរណ៍ស៊ីវិល ដែលមានកាលវិភាគធ្វើដំណើរត្រឹមត្រូវ និងមានអាជ្ញាបណ្ណត្រឹមត្រូវ ឬ

ឈ)ការចូលរួមរបស់អ្នកត្រូវបានធានារ៉ាប់រងនៅក្នុងសកម្មភាពដែលងាយមានគ្រោះថ្នាក់ ដូចជាការមុជក្រោមទឹកដែលចាំបាច់ត្រូវប្រើបំពង់អុកស៊ីសែន ការឡើងភ្នំ ការលោតឆ័ត្រយោង ការជិះជាមួយឬបើកបរក្នុងការប្រណាំង ឬកីឡាអាជីពណាមួយ។

ក្នុងករណីដែលក្រុមហ៊ុនធ្វើការបដិសេធចំពោះ សំណើទាមទារសំណង សម្រាប់អ្នកត្រូវបានធានារ៉ាប់រង ក្រុមហ៊ុននឹងបង្វិលសងបុព្វលាភធានារ៉ាប់រងដែលនឹងត្រូវបានគណនាដោយសមាមាត្រ ផ្អែកលើបុព្វលាភធានារ៉ាប់រងដែលត្រូវបង់ម្តងៗ សម្រាប់អ្នកត្រូវបានធានារ៉ាប់រងនោះ និងចំនួនថ្ងៃ គិតចាប់ពីកាលបរិច្ឆេទមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍កើតឡើង រហូតដល់កាលបរិច្ឆេទដល់កាលកំណត់បង់បុព្វលាភធានារ៉ាប់រងបន្ទាប់ឬកាលបរិច្ឆេទផុតកំណត់បណ្ណសន្យារ៉ាប់រង (ដោយយកកាលបរិច្ឆេទណាដែលមុនគេ)។

## ៧. ទីតាំងភូមិសាស្ត្រនៃការធានា

បណ្ណសន្យារ៉ាប់រងនេះផ្តល់ការការពារក្នុងព្រះរាជាណាចក្រកម្ពុជា (ផ្អែកតាម ខ និងលក្ខខណ្ឌដែលមានចែងក្នុងបណ្ណសន្យារ៉ាប់រងនេះ) ដល់អ្នកត្រូវបានធានារ៉ាប់រងក្រោមបណ្ណសន្យារ៉ាប់រងនេះ។

## ៨. លក្ខណៈសម្បត្តិរបស់អ្នកទទួលផល

អ្នកទទួលផលចម្បងនៃអត្ថប្រយោជន៍ធានារ៉ាប់រងមិនអាចត្រូវបានផ្លាស់ប្តូរ ឬដកហូត អំឡុងរយៈពេលបណ្ណសន្យារ៉ាប់រងឡើយ។

អ្នកត្រូវបានធានារ៉ាប់រង ក្រោមបណ្ណសន្យារ៉ាប់រងនេះ មានសិទ្ធិកំណត់អ្នកទទួលផលបន្ទាប់បន្សំម្នាក់ ឬច្រើននាក់ ដើម្បីទទួលអត្ថប្រយោជន៍ទាំងអស់ឬមួយផ្នែកបន្ទាប់ពីការដកចេញនូវចំនួនទឹកប្រាក់ដែលអ្នកទទួលផលចម្បងទទួលបាន (ប្រសិនបើមាន)។ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រង មិនបានកំណត់អត្រាចំណែកសម្រាប់អ្នកទទួលផលបន្ទាប់បន្សំ នោះអ្នកទទួលផលបន្ទាប់បន្សំទាំងអស់ នឹងទទួលបានអត្រាចំណែកនៃអត្ថប្រយោជន៍ស្មើៗគ្នា។ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងមិនបានកំណត់អ្នកទទួលផលបន្ទាប់បន្សំ នោះអត្ថប្រយោជន៍នៃបណ្ណសន្យារ៉ាប់រងនេះនឹងត្រូវទូទាត់ជូនទាយាទស្របច្បាប់របស់អ្នកត្រូវបានធានារ៉ាប់រង។

ប្រសិនបើអ្នកទទួលផលបន្ទាប់បន្សំម្នាក់នៃអ្នកត្រូវបានធានារ៉ាប់រងណាមួយ ត្រូវបានកំណត់ ហើយអ្នកទទួលផលបន្ទាប់បន្សំនោះបានទទួលមរណភាពមុនឬចំពេលជាមួយគ្នា នៃការកើតមានសំណងក្រោមបណ្ណសន្យារ៉ាប់រងនេះ ម្ចាស់បណ្ណសន្យារ៉ាប់រងត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរពីការផ្លាស់ប្តូរអ្នកទទួលផលបន្ទាប់បន្សំទៅក្រុមហ៊ុន។ ប្រសិនបើម្ចាស់បណ្ណសន្យារ៉ាប់រង ខកខាន ឬ មិនអាចជូនដំណឹងពីការផ្លាស់ប្តូរអ្នកទទួលផលបន្ទាប់បន្សំទៅក្រុមហ៊ុន នៅពេលដែលអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព ក្រុមហ៊ុននឹងទូទាត់អត្ថប្រយោជន៍ទៅឱ្យទាយាទស្របច្បាប់របស់អ្នកត្រូវបានធានារ៉ាប់រងនោះ។

ប្រសិនបើមានអ្នកទទួលផលបន្ទាប់បន្សំលើសពីម្នាក់នៃអ្នកត្រូវបានធានារ៉ាប់រងណាមួយ ត្រូវបានកំណត់ ហើយមានម្នាក់ក្នុងចំណោមនោះបានទទួលមរណភាពមុនការកើតមានសំណងក្រោមបណ្ណសន្យារ៉ាប់រងនេះ ម្ចាស់បណ្ណសន្យារ៉ាប់រង ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរពីការផ្លាស់ប្តូរអ្នកទទួលផលបន្ទាប់បន្សំ ឬ លក្ខខណ្ឌនៃការទូទាត់អត្ថប្រយោជន៍ដល់អ្នកទទួលផលបន្ទាប់បន្សំផ្សេងទៀតដែលនៅរស់រានមានជីវិតទៅឱ្យក្រុមហ៊ុន។ ប្រសិនបើម្ចាស់បណ្ណសន្យារ៉ាប់រង ខកខាន ឬមិនអាចជូនដំណឹងពីការផ្លាស់ប្តូរអ្នកទទួលផលបន្ទាប់បន្សំទៅក្រុមហ៊ុន នៅពេលដែលអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព ក្រុមហ៊ុននឹងទូទាត់ចំនួនទឹកប្រាក់ នៃអត្ថប្រយោជន៍ដែលនៅសល់របស់អ្នកទទួលផលបន្ទាប់បន្សំដែលទទួលមរណភាពបន្ទាប់ពីទូទាត់ការចំណាយរួមទាំងពន្ធដែលពាក់ព័ន្ធផ្សេងៗ (ប្រសិនបើមាន) ជូនទៅដល់អ្នកទទួលផលបន្ទាប់បន្សំ ដែលនៅរស់រានមានជីវិតនីមួយៗនូវចំណែកស្មើៗគ្នា។

ក្នុងអំឡុងពេលដែលអ្នកត្រូវបានធានារ៉ាប់រងនៅមានជីវិត ម្ចាស់បណ្ណសន្យារ៉ាប់រង អាចផ្លាស់ប្តូរអ្នកទទួលផលបន្ទាប់បន្សំដែលបានកំណត់ពីមុន ដោយមិនចាំបាច់មានការយល់ព្រមពីសំណាក់ អ្នកទទួលផលបន្ទាប់បន្សំណាម្នាក់ តាមរយៈលិខិតប្រកាសជាលាយលក្ខណ៍អក្សរដែលមានចុះហត្ថលេខាជាមួយអ្នកត្រូវបានធានារ៉ាប់រង និងបានដាក់ជូនក្រុមហ៊ុន។ក្រុមហ៊ុនមិនមានទំនួលខុសត្រូវផ្លូវច្បាប់សម្រាប់ការចាត់តាំង ឬការផ្លាស់ប្តូរអ្នកទទួលផលបន្ទាប់បន្សំឡើយ។

**៨.១ អាទិភាពនៃអ្នកទទួលផល**

អត្ថប្រយោជន៍ធានារ៉ាប់រង នឹងត្រូវទូទាត់ជូន អ្នកទទួលផលពេញសិទ្ធិទៅតាមលំដាប់លំដោយ អាទិភាពដូចខាងក្រោម៖

ក) អ្នកទទួលផលចម្បង

ខ) អ្នកត្រូវបានធានារ៉ាប់រង

គ) អ្នកទទួលផលបន្ទាប់បន្សំ (ក្នុងករណីដែលអ្នកទទួលផលបន្ទាប់បន្សំណាម្នាក់ទទួលមរណភាពមុនអ្នកត្រូវបានធានារ៉ាប់រង ភាគចំណែករបស់អ្នកទទួលផលបន្ទាប់បន្សំនេះ នឹងត្រូវបែងចែកដោយស្មើៗគ្នាឱ្យទៅអ្នកទទួលផលបន្ទាប់បន្សំផ្សេងទៀត)

ឃ)ទាយាទស្របច្បាប់របស់អ្នកត្រូវបានធានារ៉ាប់រង។

នៅពេលមានការអនុម័តលើការទាមទារសំណង ក្រុមហ៊ុននឹងទូទាត់សំណងជូនអ្នកទទួលផលចម្បង ទៅតាមចំនួនទឹកប្រាក់ដែលជាតម្លៃទាបជាងគេរវាងសមតុល្យកម្ចីនៅសល់របស់អ្នកត្រូវបានធានារ៉ាប់រង (ដោយចំនួនទឹកប្រាក់ធានារ៉ាប់រងនឹងត្រូវទូទាត់ ដោយមិនគិតពីសមតុល្យប្រាក់កម្ចីជាក់ស្តែងដូចបញ្ជាក់ក្នុងចំណុច ១.១០ ខាងលើ សម្រាប់ប្រភេទចំនួនទឹកប្រាក់ធានារ៉ាប់រងថយចុះ) ឬ អត្ថប្រយោជន៍មរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ (TPD)។ ចំនួនទឹកប្រាក់ដែលនៅសល់ពីការទូទាត់ជូនអ្នកទទួលផលចម្បង នឹងត្រូវបានទូទាត់ជូនទៅអ្នកទទួលផលបន្ទាប់បន្សំតាមលំដាប់អាទិភាព។

## ៩. ការកែប្រែកិច្ចសន្យាធានារ៉ាប់រង

ម្ចាស់បណ្ណសន្យារ៉ាប់រងត្រូវជូនដំណឹងជាផ្លូវការដល់ក្រុមហ៊ុន អំពីការផ្លាស់ប្តូរអ្នកត្រូវបានធានារ៉ាប់រង តាមរយៈអ៊ីម៉ែលក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃគិតចាប់ពីកាលបរិច្ឆេទផ្តល់កម្ចី ឬថ្ងៃបញ្ចប់កម្ចី ដោយមានភ្ជាប់មកជាមួយនូវព័ត៌មានជាច្បាប់ចម្លងទន់ដែលត្រូវបានកំណត់ដោយក្រុមហ៊ុន។ កាលបរិច្ឆេទដែលព័ត៌មាន នេះត្រូវបានទទួលជាផ្លូវការដោយក្រុមហ៊ុននឹងត្រូវចាត់ទុកថាជាកាលបរិច្ឆេទនៃការជូនដំណឹង។

**៩.១ ការបន្ថែមអ្នកត្រូវបានធានារ៉ាប់រង៖**

ក) ម្ចាស់បណ្ណសន្យារ៉ាប់រងអាចស្នើសុំបន្ថែមការធានារ៉ាប់រងដើម្បីការពារលើ ឥណវន្តថ្មីដោយមានការចុះហត្ថលេខា និងបោះត្រាលើបញ្ជីអ្នកត្រូវបានធានារ៉ាប់រង។ ការធានារ៉ាប់រងបន្ថែមនេះនឹងមានសុពលភាពចាប់ពីកាលបរិច្ឆេទផ្តល់កម្ចីដល់ឥណវន្ត និងត្រូវបានយល់ព្រមដោយក្រុមហ៊ុនប៉ុណ្ណោះ។

ខ) តម្លៃបុព្វលាភធានារ៉ាប់រង ដែលត្រូវបង់សម្រាប់អ្នកត្រូវបានធានារ៉ាប់រងបន្ថែមម្នាក់ៗ នឹងត្រូវបានគណនាដោយសមាមាត្រ ផ្អែកលើបុព្វលាភធានារ៉ាប់រងដែលត្រូវបង់ម្តងៗ សម្រាប់អ្នកត្រូវបានធានារ៉ាប់រងនោះ និងចំនួនថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែលកម្ចីរបស់ អ្នកត្រូវបានធានារ៉ាប់រងត្រូវបានអនុញ្ញាតិដោយម្ចាស់បណ្ណសន្យារ៉ាប់រង រហូតដល់កាលបរិច្ឆេទដល់កាលកំណត់បង់បុព្វលាភធានារ៉ាប់រងបន្ទាប់ ឬកាលបរិច្ឆេទផុតកំណត់បណ្ណសន្យារ៉ាប់រង (ដោយយកកាលបរិច្ឆេទណា ដែលមុនគេ)។

**៩.២. ការលុបចោលអ្នកត្រូវបានធានារ៉ាប់រង៖**

ក) អ្នកត្រូវបានធានារ៉ាប់រង នឹងត្រូវបានលុបចោល នៅក្នុងករណីណាមួយដូចខាងក្រោម៖

- អ្នកត្រូវបានធានារ៉ាប់រង បំពានលើបណ្ណសន្យារ៉ាប់រងនេះ ឬ
- បុព្វលាភធានារ៉ាប់រងសម្រាប់អ្នកត្រូវបានធានារ៉ាប់រង មិនត្រូវបានទូទាត់ជូន ក្រុមហ៊ុនក្នុងរយៈពេល ១០ ថ្ងៃបន្ទាប់ពីថ្ងៃដែលក្រុមហ៊ុនចេញវិក័យបត្រ ឬក្នុងរយៈពេល ១០ ថ្ងៃនៃការបិទបញ្ចប់ខែនីមួយៗ តាមការកំណត់របស់ក្រុមហ៊ុន ឬ
- នៅកាលបរិច្ឆេទផុតកំណត់នៃបណ្ណសន្យារ៉ាប់រងនេះ ឬ
- នៅកាលបរិច្ឆេទផុតកំណត់នៃកម្ចីរបស់អ្នកត្រូវបានធានារ៉ាប់រង ជាមួយនឹងម្ចាស់បណ្ណសន្យារ៉ាប់រង ឬ
- មរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍របស់អ្នកត្រូវបានធានារ៉ាប់រង ឬ

ខ) ក្នុងករណីមានការដកចេញអ្នកត្រូវបានធានារ៉ាប់រងណាម្នាក់ ការបង្វិលសងបុព្វលាភធានារ៉ាប់រង នឹងត្រូវបានគណនាដោយសមាមាត្រ ផ្អែកលើបុព្វលាភធានារ៉ាប់រងដែលត្រូវបង់ម្តងៗ សម្រាប់អ្នកត្រូវបានធានារ៉ាប់រងនោះ និងចំនួនថ្ងៃ គិតចាប់ពីកាលបរិច្ឆេទបញ្ចប់ការធានារ៉ាប់រងរបស់អ្នកត្រូវបានធានារ៉ាប់រង រហូតដល់កាលបរិច្ឆេទដល់កាលកំណត់បង់បុព្វលាភធានារ៉ាប់រងបន្ទាប់ ឬកាលបរិច្ឆេទផុតកំណត់បណ្ណសន្យារ៉ាប់រង (ដោយយកកាលបរិច្ឆេទណាដែលមុនគេ)។ យ៉ាងណាមិញ ប្រសិនបើមានការទាមទារសំណងជាក់លាក់ណាមួយនៅមុនកាលបរិច្ឆេទនៃការដកចេញនូវអ្នកត្រូវបានធានារ៉ាប់រង នោះនឹងមិនមានការសងនូវបុព្វលាភធានារ៉ាប់រងមកវិញ សម្រាប់អ្នកត្រូវបានធានារ៉ាប់រងនោះឡើយ។

## ១០. ការបន្តកិច្ចសន្យាធានារ៉ាប់រង

បណ្ណសន្យារ៉ាប់រងនេះត្រូវបានចេញសម្រាប់រយៈពេលមួយឆ្នាំ ហើយនឹងត្រូវបន្តជាថ្មីដោយស្វ័យប្រវត្តិនៅចុងឆ្នាំនៃបណ្ណសន្យារ៉ាប់រងនីមួយៗ តាមការកំណត់ដោយក្រុមហ៊ុន។ ក្រុមហ៊ុន សូមរក្សាសិទ្ធិក្នុងការកែប្រែ ឬកែតម្រូវអត្រាបុព្វលាភធានារ៉ាប់រង ខ និងលក្ខខណ្ឌ នៅពេលដល់ខួបនៃបណ្ណសន្យារ៉ាប់រងណាមួយ ដោយជូនដំណឹងដល់ម្ចាស់បណ្ណសន្យារ៉ាប់រងជាលាយលក្ខណ៍អក្សរ យ៉ាងហោចណាស់សាមសិប (៣០) ថ្ងៃ មុនដល់ខួបនៃបណ្ណសន្យារ៉ាប់រង។

នៅពេលបន្តបណ្ណសន្យារ៉ាប់រង ក្រុមហ៊ុននឹងមិនផ្តល់ការធានារ៉ាប់រង ឬអត្ថប្រយោជន៍ណាមួយដល់អ្នកត្រូវបានធានារ៉ាប់រងណាម្នាក់ដែលមានអាយុលើសពី ៦៥ (ហុកសិបប្រាំ) ឆ្នាំដោយផ្អែកលើថ្ងៃខួបកំណើតចុងក្រោយរបស់គាត់ឡើយ។

ម្ចាស់បណ្ណសន្យារ៉ាប់រង និង/ឬក្រុមហ៊ុនមានសិទ្ធិក្នុងការមិនបន្តសុពលភាពកិច្ចសន្យាធានារ៉ាប់រងនេះ។ ក្នុងករណីក្រុមហ៊ុនបដិសេធមិនបន្តសុពលភាពកិច្ចសន្យាធានារ៉ាប់រងនេះ ក្រុមហ៊ុននឹងជូនដំណឹងដល់ម្ចាស់បណ្ណសន្យារ៉ាប់រងជាលាយលក្ខណ៍អក្សរ មុនកាលបរិច្ឆេទបន្តសុពលភាពកិច្ចសន្យាធានារ៉ាប់រងនេះ។

## ១១. ការបញ្ចប់កិច្ចសន្យាធានារ៉ាប់រង

ក្នុងករណីម្ចាស់បណ្ណសន្យារ៉ាប់រង មានបំណងបញ្ចប់បណ្ណសន្យារ៉ាប់រងនេះ ម្ចាស់បណ្ណសន្យារ៉ាប់រង ត្រូវជូនដំណឹងមកកាន់ក្រុមហ៊ុនគ្រប់ពេលមុនថ្ងៃបង់បុព្វលាភធានារ៉ាប់រងបន្ទាប់។ បណ្ណសន្យារ៉ាប់រងនេះនឹងបញ្ចប់បន្ទាប់ពី ក្រុមហ៊ុនទទួលបាននូវការជូនដំណឹងជាលាយលក្ខណ៍អក្សរនេះ ហើយរាល់អត្ថប្រយោជន៍និងសិទ្ធិនៅក្រោមបណ្ណសន្យារ៉ាប់រងនេះនឹងផុតរលត់។ ករណីនេះដែរ ក្រុមហ៊ុននឹងសងត្រលប់នូវបុព្វលាភធានារ៉ាប់រងដែលនៅសល់តាមវិធីគណនាដោយសមាមាត្រ ផ្អែកលើបុព្វលាភធានារ៉ាប់រងដែលត្រូវបង់ម្តងៗសរុប និងចំនួនថ្ងៃ គិតចាប់ពីកាលបរិច្ឆេទបញ្ចប់បណ្ណសន្យារ៉ាប់រង រហូតដល់កាលបរិច្ឆេទដល់កាលកំណត់បង់បុព្វលាភធានារ៉ាប់រងបន្ទាប់ ឬកាលបរិច្ឆេទផុតកំណត់បណ្ណសន្យារ៉ាប់រង (ដោយយកកាលបរិច្ឆេទណាដែលមុនគេ)។

ការបញ្ចប់បណ្ណសន្យារ៉ាប់រងនេះ នឹងមិនប៉ះពាល់ដល់សិទ្ធិណាមួយ ក្នុងការទាមទារសំណងដែលបានកើតឡើងមុនកាលបរិច្ឆេទបញ្ចប់នោះទេ។ ប្រសិនបើមានការបង់ប្រាក់បុព្វលាភជូនក្រុមហ៊ុនបន្ទាប់ពីការបញ្ចប់នៃបណ្ណសន្យារ៉ាប់រងនេះ ក្រុមហ៊ុននឹងប្រគល់បុព្វលាភធានារ៉ាប់រងនោះវិញដោយ មិនមានទំនួលខុសត្រូវបន្ថែមទៀតណាមួយឡើយ។

## ១២. ការលុបចោលកិច្ចសន្យាធានារ៉ាប់រង

បណ្ណសន្យារ៉ាប់រងនេះ នឹងត្រូវបានលុបចោល នៅពេលដែលហេតុការណ៍ណាមួយខាងក្រោមកើតឡើង៖

ក) នៅកាលបរិច្ឆេទដល់កាលកំណត់នៃបណ្ណសន្យារ៉ាប់រងនេះដូចដែលមានបង្ហាញនៅលើ វិញ្ញាបនបត្រធានារ៉ាប់រងអាយុជីវិតលើកម្ចីជាក្រុម ឬឯកសារភ្ជាប់ផ្សេងៗទៀតនៃបណ្ណសន្យារ៉ាប់រងនេះ លើកលែងតែបណ្ណសន្យារ៉ាប់រងនេះត្រូវបានបន្តថ្មីឡើងវិញ ឬ

ខ) បុព្វលាភធានារ៉ាប់រងនៃបណ្ណសន្យារ៉ាប់រងនេះមិនត្រូវបានទូទាត់ជូនក្រុមហ៊ុនបន្ទាប់ពីរយៈពេល អនុគ្រោះ ឬ

គ) ករណីផ្សេងទៀតដែលមានចែងក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ឬ

ឃ) ម្ចាស់បណ្ណសន្យារ៉ាប់រង បំពានលើបណ្ណសន្យារ៉ាប់រងនេះ ឬ

ង) ក្រុមហ៊ុនរក្សាសិទ្ធិក្នុងការលុបចោលបណ្ណសន្យារ៉ាប់រង ករណីម្ចាស់បណ្ណសន្យារ៉ាប់រង និង/ឬ អ្នកត្រូវបានធានារ៉ាប់រង ក្រោមបណ្ណសន្យារ៉ាប់រងនេះផ្តល់ព័ត៌មានមិនពិត ឬមិនត្រឹមត្រូវ ដែលមានសារៈសំខាន់សម្រាប់ការវាយតម្លៃអំពីហានិភ័យដើម្បីចេញបណ្ណសន្យារ៉ាប់រង និងការធានារ៉ាប់រងនៃបណ្ណសន្យារ៉ាប់រងនេះ ឬ

ច) ករណីផ្សេងទៀតដូចមានចែងនៅក្នុងបណ្ណសន្យារ៉ាប់រងនេះ។

នៅពេលមានការលុបចោលបណ្ណសន្យារ៉ាប់រងនេះ ដូចក្នុងចំណុច គ ឃ ង និង ច នៃប្រការនេះ ក្រុមហ៊ុននឹងសងត្រលប់នូវបុព្វលាភធានារ៉ាប់រងដែលនៅសល់ តាមវិធីគណនាដូចគ្នាដែលមានចែងក្នុងប្រការ ១១ នៃបណ្ណសន្យារ៉ាប់រងនេះ។

## ១៣ ការទាមទារសំណង

ក្នុងករណីមានការទាមទារសំណងនៅក្រោមបណ្ណសន្យារ៉ាប់រងនេះ ក្រុមហ៊ុននឹងទូទាត់អត្ថប្រយោជន៍ធានារ៉ាប់រងក្រោមបណ្ណសន្យារ៉ាប់រងនេះទៅឱ្យម្ចាស់បណ្ណសន្យារ៉ាប់រង អ្នកត្រូវបានធានារ៉ាប់រង ឬអ្នកទទួលផលបន្ទាប់បន្សំ ឬទាយាទស្របច្បាប់របស់អ្នកត្រូវបានធានារ៉ាប់រង បន្ទាប់ពីក្រុមហ៊ុនបានរកឃើញថាការទាមទារសំណងនេះគឺស្របតាមខ និងលក្ខខណ្ឌនៃបណ្ណសន្យារ៉ាប់រង។

### ១៣.១ នីតិវិធីនៃការផ្តល់ព័ត៌មាន

➤ **ការជូនដំណឹងអំពីមរណភាពបណ្តាលមកពីមូលហេតុទូទៅ ឬបណ្តាលមកពីគ្រោះថ្នាក់៖**

ក្នុងករណីអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព ម្ចាស់បណ្ណសន្យារ៉ាប់រង ឬអ្នកទទួលផលបន្ទាប់បន្សំ ត្រូវជូនដំណឹងជាបន្ទាន់ដល់ក្រុមហ៊ុន គិតចាប់ពីកាលបរិច្ឆេទទទួលមរណភាព របស់អ្នកត្រូវបានធានារ៉ាប់រង ឬគិតចាប់ពីថ្ងៃដែលម្ចាស់បណ្ណសន្យារ៉ាប់រង ឬអ្នកទទួលផលបន្ទាប់បន្សំបានដឹងអំពីវត្តមាននៃបណ្ណសន្យារ៉ាប់រង តាមរយៈមធ្យោបាយដូចជា ជូនដំណឹងដោយផ្ទាល់ ទំនាក់ទំនងតាមទូរស័ព្ទ ផ្ញើសារតាមប្រព័ន្ធអេឡិចត្រូនិក ឬលិខិតជាលាយលក្ខណ៍អក្សរ លើកលែងតែក្នុងករណីដែលអាចបញ្ជាក់បានថា មានមូលហេតុសមរម្យ ដែលធ្វើអោយមានការពន្យាពេលទៅលើការជូនដំណឹងអំពីមរណភាពនោះ ឬក្នុងករណីដែលម្ចាស់បណ្ណសន្យារ៉ាប់រង ឬអ្នកទទួលផលបន្ទាប់បន្សំ មិនបានដឹងថាអ្នកត្រូវបានធានារ៉ាប់រងនោះ មានបណ្ណសន្យារ៉ាប់រង។

➤ **ការជូនដំណឹងអំពីពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ (TPD) បណ្តាលមកពីមូលហេតុទូទៅ ឬបណ្តាលមកពីគ្រោះថ្នាក់៖**

ក្នុងករណីពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ (TPD) ដែលបណ្តាលមកពីមូលហេតុទូទៅ ឬបណ្តាលមកពីគ្រោះថ្នាក់ ពិការភាពនោះត្រូវតែមានការបញ្ជាក់ដោយបុគ្គលដែលប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រ/គ្រូពេទ្យ/វេជ្ជបណ្ឌិត ដែលបានចុះបញ្ជីត្រឹមត្រូវ ដោយត្រូវបង្ហាញ ភស្តុតាង ដែលអាចជឿជាក់បានថាមានពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ (TPD)។ ដើម្បីបញ្ជាក់បានថាជាការខ្វិន ឬបាត់បង់សមត្ថភាពប្រើប្រាស់ទាំងស្រុង និងមិនអាចជាសះស្បើយជាអចិន្ត្រៃយ៍ ពិការភាពនោះត្រូវតែបានកើតឡើងបន្តក្នុងរយៈពេលយ៉ាងហោចណាស់ ១៨០ (មួយរយប៉ែតសិប) ថ្ងៃ គិតចាប់ពីថ្ងៃដែលមានគ្រោះថ្នាក់ ឬថ្ងៃដែលធ្វើរោគវិនិច្ឆ័យ។ នៅក្នុងករណីបាត់បង់ទាំងស្រុងនៃដៃម្ខាង ឬដៃទាំងពីរ ឬជើងម្ខាង ឬជើងទាំងពីរ ឬភ្នែកម្ខាង ឬភ្នែកទាំងពីរ នោះការបញ្ជាក់ករណីបាត់បង់នេះអាចត្រូវបានធ្វើឡើងគ្រប់ពេល។

ក្រុមហ៊ុនត្រូវតែទទួលបាននូវការជូនដំណឹងជាបន្ទាន់ គិតចាប់ពីថ្ងៃដែលគ្រោះថ្នាក់បានកើតឡើង ឬថ្ងៃដែលធ្វើរោគវិនិច្ឆ័យ តាមរយៈមធ្យោបាយដូចជា ជូនដំណឹងដោយផ្ទាល់ ទំនាក់ទំនងតាមទូរស័ព្ទ ផ្ញើសារតាមប្រព័ន្ធអេឡិចត្រូនិក ឬលិខិតជាលាយលក្ខណ៍អក្សរ លើកលែងតែក្នុងករណីដែលអាចបញ្ជាក់បានថា មានមូលហេតុសមរម្យ ដែលធ្វើអោយមានការពន្យាពេលទៅលើការជូនដំណឹងអំពីពិការភាពនោះ។

### ១៣.២ ឯកសារតម្រូវសម្រាប់ការទាមទារសំណង

➤ **ករណីមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ (TPD)៖**

ក) ពាក្យស្នើសុំទាមទារសំណង
ខ) របាយការណ៍គ្រូពេទ្យសម្រាប់ករណីមរណភាព (ប្រសិនបើទទួលមរណភាពនៅក្នុងមន្ទីរពេទ្យ ឬគ្លីនិក) ឬរបាយការណ៍គ្រូពេទ្យ (ប្រសិនបើមាន)
គ) សេចក្តីចម្លងសំបុត្រមរណភាពដែលបញ្ជាក់ដោយអាជ្ញាធរមានសមត្ថកិច្ច ឬសេចក្តីបញ្ជាក់ ឬលិខិតបញ្ជាក់វេជ្ជសាស្ត្រអំពីពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ចេញដោយមន្ទីរពេទ្យ ឬគ្លីនិក
ឃ)ច្បាប់ថតចម្លងនៃអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន និងសៀវភៅគ្រួសារ សំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ ឬឯកសារផ្សេងទៀតរបស់អ្នកទទួលផលដែលបញ្ជាក់អំពីទំនាក់ទំនងជាមួយអ្នកត្រូវបានធានារ៉ាប់រង
ង) ច្បាប់ថតចម្លងនៃរបាយការណ៍វេជ្ជសាស្ត្រ (ភស្តុតាងទាក់ទងនឹងការព្យាបាល និងឯកសារបញ្ជាក់រោគវិនិច្ឆ័យ)
ច) ឯកសារបញ្ជាក់ប្រាក់នៅជំពាក់ធនាគារ ឬគ្រឹះស្ថានហិរញ្ញវត្ថុចុងក្រោយគេបង្អស់
ឆ) ច្បាប់ថតចម្លងនៃកិច្ចសន្យាកម្ចី និងតារាងកម្ចី
ជ) ច្បាប់ថតចម្លងនៃរបាយការណ៍ប៉ូលីស (ប្រសិនបើមាន)
ឈ)ច្បាប់ថតចម្លងនៃរបាយការណ៍កោសល្យវិច័យ (ប្រសិនបើមាន)
ញ)លិខិតយល់ព្រមបង្ហាញព័ត៌មានដែលទាក់ទងនឹងប្រវត្តិជំងឺរបស់អ្នកត្រូវបានធានារ៉ាប់រង (ប្រសិនបើមាន)
ដ) លិខិតបញ្ជាក់ផ្សេងៗពីអាជ្ញាធរមានសមត្ថកិច្ច ឬឯកសារផ្សេងទៀតដែលមានសារៈសំខាន់ក្នុងការវាយតម្លៃលើការទូទាត់សំណង (ប្រសិនបើមាន)

### ១៣.៣ រយៈពេលអតិបរមានៃការដោះស្រាយសំណងធានារ៉ាប់រងជូនអតិថិជន

នៅពេលមានសំណើទាមទារសំណងកើតឡើង ក្រុមហ៊ុនត្រូវឆ្លើយតបទៅនឹងអ្នកទាមទារសំណង អំពីការបដិសេធ ឬការសម្រេចផ្តល់សំណងធានារ៉ាប់រងជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីក្រុមហ៊ុនបានទទួលពាក្យស្នើសុំទាមទារសំណងពេញលេញ ព្រមទាំងឯកសារតម្រូវដែលពាក់ព័ន្ធផ្សេងៗគ្រប់គ្រាន់ ឬបន្ទាប់ពីទទួលបានភស្តុតាងគ្រប់គ្រាន់ដែលអាចទុកចិត្តបាន សម្រាប់បញ្ជាក់ថាការទាមទារសំណងពិតជាមានលក្ខណៈត្រឹមត្រូវ។ ភស្តុតាងគ្រប់គ្រាន់សម្រាប់ការសម្រេចចិត្តទៅលើការទាមទារសំណង គឺសំដៅលើការបញ្ចប់នៃដំណើរការនៃការវាយតម្លៃការទាមទារសំណងនោះ។

### ១៣.៤ នីតិវិធីនៃការទូទាត់សំណង

ការទូទាត់ប្រាក់សំណងជូនអ្នកទាមទារសំណងធានារ៉ាប់រង អាចធ្វើឡើងដោយមូលប្បទានបត្រ ការផ្ទេរប្រាក់តាមធនាគារ ឬដោយវិធីសាស្ត្រសមស្របណាមួយផ្សេងទៀតក្នុងរយៈពេល ៣ (បី) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីអ្នកទាមទារសំណងធានារ៉ាប់រងឯកភាពទទួលយកសំណងធានារ៉ាប់រង។

## ១៤. ការរក្សាព័ត៌មានសម្ងាត់

រាល់ព័ត៌មានដែលបានផ្តល់ជូនក្រុមហ៊ុន នឹងត្រូវរក្សាជាព័ត៌មានសម្ងាត់ហើយគ្មានព័ត៌មានផ្ទាល់ខ្លួនណាមួយនឹងត្រូវបញ្ចេញទៅឱ្យភាគីទីបីដោយគ្មានការយល់ព្រមជាមុនឡើយ លើកលែងតែបានតម្រូវ ឬអនុញ្ញាតឱ្យដោយច្បាប់ ឬបទប្បញ្ញត្តិជាធរមាន។

## ១៥. ការផ្សះផ្សាវិវាទ

ចំពោះគ្រប់វិវាទនៃកិច្ចសន្យាធានារ៉ាប់រងនេះដែលពាក់ព័ន្ធនឹងអាជីវកម្មធានារ៉ាប់រង ភាគីណាមួយនៃភាគីវិវាទអាចនាំយកវិវាទទៅជូននិយ័តករធានារ៉ាប់រងកម្ពុជា ដើម្បីសម្រុះសម្រួលធ្វើការផ្សះផ្សាវិវាទ មុនប្តឹងទៅវេទិការមជ្ឈត្តកម្ម ឬតុលាការមានសមត្ថកិច្ចលើកលែងតែរឿងព្រហ្មទណ្ឌ។

## ១៦. ដែនយុត្តាធិការ

កិច្ចសន្យាធានារ៉ាប់រងនេះ ត្រូវអនុវត្តក្រោមដែនយុត្តាធិការនៃព្រះរាជាណាចក្រកម្ពុជា។

## ១៧. កាតព្វកិច្ចក្នុងការបង្ហាញព័ត៌មាន

ម្ចាស់បណ្ណសន្យារ៉ាប់រង និងអ្នកត្រូវបានធានារ៉ាប់រង មានកាតព្វកិច្ចក្នុងការបង្ហាញ និងផ្តល់ឱ្យក្រុមហ៊ុននូវព័ត៌មានគ្រប់គ្រាន់ និងត្រឹមត្រូវតាមតម្រូវការរបស់ក្រុមហ៊ុន ដើម្បីអាចធ្វើការវាយតម្លៃលើការស្នើសុំបណ្ណសន្យារ៉ាប់រងនេះ។ ប្រសិនបើ កាលបរិច្ឆេទដាក់ពាក្យស្នើសុំធានារ៉ាប់រងកើតឡើងមុនកាលបរិច្ឆេទចាប់ផ្តើមបណ្ណសន្យារ៉ាប់រង ម្ចាស់បណ្ណសន្យារ៉ាប់រង និងអ្នកត្រូវបានធានារ៉ាប់រង មានកាតព្វកិច្ចជូនដំណឹងដល់ក្រុមហ៊ុនអំពីការផ្លាស់ប្តូរណាមួយនៃមុខរបរ ស្ថានភាពសុខភាព ឬសកម្មភាពទាក់ទងនឹងអ្នកត្រូវបានធានារ៉ាប់រង នៅចន្លោះរវាងកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំធានារ៉ាប់រង ឬការពិនិត្យសុខភាពចុងក្រោយ និងកាលបរិច្ឆេទចេញបណ្ណសន្យារ៉ាប់រង ដែលការផ្លាស់ប្តូរទាំងអស់នេះអាចផ្លាស់ប្តូរលទ្ធផលនៃការវាយតម្លៃហានិភ័យនៃបណ្ណសន្យារ៉ាប់រងនេះ។ ការពិនិត្យសុខភាព (ប្រសិនបើមាន) នឹងមិនអាចជំនួសលើកាតព្វកិច្ចរបស់ម្ចាស់បណ្ណសន្យារ៉ាប់រង ឬអ្នកត្រូវបានធានារ៉ាប់រងក្នុងការបង្ហាញនូវព័ត៌មានដែលមានលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវនោះឡើយ។

គិតចាប់តាំងពី កិច្ចសន្យាធានារ៉ាប់រងនេះចាប់ផ្តើមមានសុពលភាព ប្រសិនបើក្រុមហ៊ុនអាចបញ្ជាក់បានថា ម្ចាស់បណ្ណសន្យារ៉ាប់រង ឬអ្នកត្រូវបានធានារ៉ាប់រងបានផ្តល់នូវព័ត៌មានដែលមិនពេញលេញ ឬមិនត្រឹមត្រូវដោយចេតនា ដែលអាចកែប្រែនូវលទ្ធផល នៃការធ្វើសេចក្តីសម្រេចលើការវាយតម្លៃហានិភ័យកន្លងមក នោះក្រុមហ៊ុនមានសិទ្ធិលុបចោលការការពារទៅលើអ្នកត្រូវបានធានារ៉ាប់រងដែលបានផ្តល់ព័ត៌មាន មិនពេញលេញ ឬមិនត្រឹមត្រូវនោះ ឬលុបចោលបណ្ណសន្យារ៉ាប់រងនេះទាំងមូល ជាឯកតោភាគីបានគ្រប់ពេលក្នុងអំឡុងពេលដែលបណ្ណសន្យារ៉ាប់រងនេះកំពុងមានសុពលភាព។